**រាជបណ្ឌិត្យសភាកម្ពុជា**
**វិទ្យាស្ថានសិក្សាចិន**
នាយកដ្ឋានសេដ្ឋកិច្ចនិងការអភិវឌ្ឍចិន

# និន្នាការសេដ្ឋកិច្ចសង្គម ចិន

## សីហា ២០២៥



## បុព្វកថាអ្នករៀបរៀង

ខែកក្កដា ឆ្នាំ ២០២៥ ការនាំចេញទំនិញរបស់ចិនមានការថយចុះ ធៀបនឹងខែមុន តែកើនឡើង ធៀបរយៈពេលដូចគ្នាឆ្នាំមុន ការនាំចូលប្រទេសចិន មានការកើនឡើង ធៀបនឹងខែមុន និងរយៈពេលដូច គ្នាឆ្នាំមុន ដែលបង្ហាញពីការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក។ ជម្លោះថៃនិងកម្ពុជា បានធូរស្រាល ដោយភាគីទាំងសងខាង មិនមានការប្រឈមមុខដាក់គ្នាជាប្រដាប់អាវុធ។

ជាអ្នករៀបរៀងខ្ញុំបាទ ក្នុងពេលបំពេញភារកិច្ច ក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយខ្ញុំបាទ បានរៀនសូត្រពី វិធីសាស្ត្រគណនាកំណើន ពី ឯកឧត្តម គឹម ផល្លា ជាអគ្គនាយករង នៃអគ្គនាយកដ្ឋាន គោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង មុនចូលបម្រើការងារក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំបាទបានរៀនសូត្រពីស្ថិតិអនុវត្តិពី អ្នកជំនាញ (Expert) នៃ ធនាគារពិភពលោក (World Bank) សាស្ត្រាចារ្យ Michele Bruni ក្នុងពេលខ្ញុំបម្រើការក្នុង ទីភ្នាក់ងារជាតិមុខរបរនិងការងារ និងខ្ញុំបាន សិក្សាស្ថិតិវិទ្យា និងសេដ្ឋមាត្រសាស្ត្រ ពីសាស្ត្រាចារ្យ Honda Yuzo និងសាស្ត្រាចារ្យ Ban Kanami នៃ សាកលវិទ្យាល័យ Osaka និងសាស្ត្រាចារ្យ Maesono Yoshihiko និង សាស្ត្រាចារ្យ Saeki Chikayoshi នៃសាកលវិទ្យាល័យ Kyushu។

ខ្ញុំបាទសង្ឃឹម កិច្ចការ ស្រាវជ្រាវ និងតាមដានព័ត៌មានសេដ្ឋកិច្ចសង្គម ចិន នេះ នឹងអាចជាអត្ថ ប្រយោជន៍ ដល់អ្នកសិក្សាស្រាវជ្រាវពីសេដ្ឋកិច្ចសង្គមចិន។ របាយការណ៍នេះ គ្រាន់តែជា Flash Report ដែលមិនស៊ីជម្រៅ សម្រាប់សេដ្ឋកិច្ចជាក់ស្តែង។

ថ្ងៃសុក្រ ៦កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩
ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៥
អ្នករៀបរៀង
ជឹម សុជាតិ (MSc. In Economics)

# ក្រាហ្វិកនៃនិន្នាការសេដ្ឋកិច្ចចិន

ការនាំចេញរបស់សេដ្ឋកិច្ចចិន (ប៊ីលាន$)




ប្រភព៖ Ministry of Commerce People Republic of China

ការនាំចូលរបស់សេដ្ឋកិច្ចចិន (ប៊ីលាន$)




ប្រភព៖ Ministry of Commerce People

អតិផរណារបស់ចិន




ប្រភព៖ NBS

អត្រាផ្តូរប្រាក់យ៉ន/$




ប្រភព៖ China Foreign Exchange Trade System

## ស្ថានភាពនិន្នាការសេដ្ឋកិច្ចចិន

នៅខែកក្កដា ឆ្នាំ២០២៥ ប្រទេសចិនបាននាំចេញទំនិញមានតម្លៃ ៣២១,៨ ប៊ីលានដុល្លារ ថយចុះ ១,០% ធៀបនឹងខែមិថុនាឆ្នាំ ២០២៥ ធៀបរយៈពេលដូចគ្នាឆ្នាំមុនការនាំចេញកើនឡើង ៧,២% ចំណែកការនាំចូលរបស់ចិនមាន ២២៣,៥ ប៊ីលានដុល្លារ កើនឡើង ៦,២% ធៀបនឹងខែមិថុនាឆ្នាំ ២០២៥ ធៀបរយៈពេលដូចគ្នាឆ្នាំមុនការនាំចូលកើនឡើង ៤,០%។ នៅខែកក្កដា ឆ្នាំ ២០២៥ សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ជាតិ (CPI) YoY នៅតែដដែលពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងនោះ CPI នៅក្នុងទីក្រុងនៅតែដដែល ខណៈCPI នៅតាមជនបទបានធ្លាក់ចុះ ០,៣%។ នៅក្នុងខែកក្កដា CPI MoM បានកើនឡើង ០,៤%ក្នុងមួយខែ ក្នុងនោះ តម្លៃនៅក្នុងទីក្រុងបានកើនឡើង ០,៤% និងតម្លៃនៅតាមជនបទកើនឡើង ០,៣%។ ក្នុងខែសីហា ២០២៥ រូបិយបណ្ណយ័ន ចិនបានឡើងថ្លៃ ដល់ 7.11 យ័ន/$។

កំណើន GDP របស់ប្រទេសចិនមានស្ថិរភាពក្នុងត្រីមាសទី ២ ឆ្នាំ ២០២៥ បើទោះបីជាមានការធ្លាក់ចុះតិចតួចក៏ដោយ។ សេដ្ឋកិច្ចបានកើនឡើង ៥,២% ពីមួយឆ្នាំទៅមួយឆ្នាំ ធ្លាក់ចុះពី ៥,៤%នៅក្នុងត្រីមាសមុន។ សម្រាប់ឆមាសទីមួយនៃឆ្នាំនេះ GDP របស់ប្រទេសចិនក៏បានកើនឡើងផងដែរ ៥,២%លើសពីគោលដៅកំណើនប្រចាំឆ្នាំរបស់រដ្ឋាភិបាលប្រហែល ៥%។ ប៉ុន្តែកំណើន GDP មានការកើនឡើងបរិត្តផរណា និងឥទ្ធិពលមូលដ្ឋាននៃកំណើនទាបនៅក្នុងរយៈពេលកាលពីឆ្នាំមុន។ លើសពីនោះគឺជាបញ្ហារចនាសម្ព័ន្ធ Over Capacity។ រដ្ឋាភិបាលបានឆ្លើយតបដោយដាក់ចេញនូវវិធានការគាំទ្របន្ថែមទៀត ដើម្បីជំរុញការប្រើប្រាស់ និងបានផ្តួចផ្តើមកំណែទម្រង់សំខាន់ៗដែលមានសក្តានុពលក្នុងគោលបំណងដោះស្រាយបញ្ហា Over Capacity ក្នុងវិស័យសំខាន់ៗ។ វិធានការគាំទ្រដែលបានណែនាំតាំងពីពាក់កណ្តាលឆ្នាំ 2024 បានជួយបង្កើនការប្រើប្រាស់។

**<u>អនុសាសន៍របស់ លោកប្រធានាធិបតីចិន ៖</u>**

លោកកប្រធានាធិបតីចិន ស៊ី ជីងភីន បានទស្សនកិច្ចនៅឯទីលាន Potala Palace ក្នុងទីក្រុង Lhasa នៃតំបន់ស្វយ័ត ទីបេ (Xizang) ដើម្បីប្រារព្ធខួបលើកទី ៦០ នៃការបង្កើតតំបន់ទីបេ ។ ការបង្កើតតំបន់ស្វយ័ត Xizang នៅខែកញ្ញា ឆ្នាំ បានធ្វើឲ្យតំបន់ទីបេ បានបោះជំហានយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ដោយគោលនយោបាយនៃប្រព័ន្ធសង្គមនិយមរបស់ប្រទេសចិន ។

សៀវភៅបាឋកថារបស់ លោកប្រធានាធិបតីចិន ស៊ី ជីងភីន ចំនួន ២ភាគ ត្រូវបានបោះពុម្ពផ្សាយដោយ Institute of Party History and Literature of the CPC Central Committee ស្តីអំពីកំណែទម្រង់ "Why reform should be comprehensively deepened in the new era and how to advance such reform" ។ សៀវភៅភាគទីមួយមានការប្រមូលផ្តុំនៃស្នាដៃសំខាន់ៗចំនួន ៧៣ ដោយលោកប្រធានាធិបតី ស៊ី ជីងភីន ពន្យល់អំពីការពង្រឹងកំណែទម្រង់យ៉ាងទូលំទូលាយរវាងខែធ្នូ ឆ្នាំ ២០១២ និងខែធ្នូ ឆ្នាំ ២០១៨ ។ សៀវភៅភាគទីពីរមានការចងក្រងចំនួន ៩២ ចាប់ពីខែមករា ឆ្នាំ ២០១៩ ដល់ខែមេសា ឆ្នាំ ២០២៥ ដែលមួយចំនួនត្រូវបានបោះពុម្ពជាលើកដំបូង ។

លោកប្រធានាធិបតីចិន ស៊ី ជីងភីន នៅក្នុងកិច្ចសន្ទនាទូរសព្ទជាមួយ លោកប្រធានាធិបតីរុស្ស៊ី វ្ល៉ាឌីមៀរ ពូទីន បាននិយាយថា "China will remain consistent in its position on the Ukraine crisis and continue to promote peace talks no matter how the situation evolves. Chinese side is glad to see Russia and the United States maintain contact, improve their relations and promote the political settlement of the Ukraine crisis." ។ លោកប្រធានាធិបតីរុស្ស៊ី វ្ល៉ាឌីមៀរ ពូទីន បាននិយាយថា "Russia highly appreciates the constructive role China has been playing in the political settlement of the crisis, adding that the comprehensive strategic partnership of coordination between Russia and China will not change under any circumstances." ។

**សេដ្ឋកិច្ចនយោបាយ៖** សេដ្ឋកិច្ចរបស់ប្រទេសចិនមានកំណើនលើសការរំពឹងទុក បើទោះបីជាពន្ធរបស់សហរដ្ឋអាមេរិក និងវិបត្តិអូសបន្លាយក្នុងទីផ្សារអចលនទ្រព្យ។ សេដ្ឋកិច្ចធំទីពីររបស់ពិភពលោកបានកើនឡើង ៥,២% ក្នុងរយៈពេលបីខែដល់ចុងខែមិថុនា ២០២៥ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ប្រទេសចិនបានសម្រួលគំរូកំណើន Growth Model ខណៈភាពតានតឹងភូមិសាស្ត្រនយោបាយនាំឲ្យការនាំចេញយឺត និងផលចំណេញពីការវិនិយោគធ្លាក់ចុះ ដែលរដ្ឋាភិបាលចិនបានបង្កើនតម្រូវការក្នុងស្រុក។

ប្រធានាធិបតីសហរដ្ឋអាមេរិក លោក ដូណាល់ ត្រាំ បានប្រើប្រាស់ការដាក់ពន្ធ ជាឥទ្ធិពល ដើម្បីទាមទារឱ្យបញ្ឈប់ជាបន្ទាន់នូវជម្លោះប្រដាប់អាវុធរវាងថៃ នឹងកម្ពុជា។ថ្លែងទៅកាន់ Fox News នៅលើយន្តហោះ Air Force One លោក Trump បាននិយាយថា ទីក្រុង វ៉ាស៊ីនតោន លោកកំពុងបន្តឃ្លាំមើលជម្លោះព្រំដែនកម្ពុជា-ថៃ ហើយបានអំពាវនាវឱ្យមានការរក្សាបទឈប់បាញ់រវាងប្រទេសទាំងពីរ។

បទឈប់បាញ់រវាងកម្ពុជា និងថៃបានចូលជាធរមាននៅពាក់កណ្តាលអធ្រាត្រ នៅថ្ងៃ២៨ កក្កដា ប៉ុន្មានម៉ោងបន្ទាប់បានយល់ព្រមបញ្ឈប់ជម្លោះដ៏ធំ ក្នុងរយៈពេលជាងមួយទសវត្សរ៍ បន្ទាប់ពីមានការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លារយៈពេលប្រាំថ្ងៃ ដែលបានជម្លៀសមនុស្សជាង ៣០០ ០០០ នាក់។ បន្ទាប់ពីកិច្ចខិតខំប្រឹងប្រែងរបស់ម៉ាឡេស៊ី ដែលជាប្រធានអាស៊ាន សហរដ្ឋអាមេរិក និងចិន ដើម្បីថ្នាក់ដឹកនាំប្រទេសទាំងពីរបានព្រមព្រៀងគ្នាក្នុងអំឡុងកិច្ចពិភាក្សានៅទីក្រុង Putrajaya ដើម្បីបញ្ចប់ជម្លោះ និងបង្កើតយន្តការមួយដើម្បីអនុវត្តបទឈប់បាញ់។

**សេដ្ឋកិច្ចសង្គម៖** ក្រសួងហិរញ្ញវត្ថុរបស់ចិនបានចេញផ្សាយទិន្នន័យចំណូលសារពើពន្ធ និងចំណាយសម្រាប់រយៈពេល ៧ ខែដំបូងនៃឆ្នាំ ២០២៥។ ចាប់ពីខែមករាដល់ខែកក្កដា ២០២៥ ចំណូលថវិកាសាធារណៈទូទៅរបស់ជាតិមានចំនួន 13.5839 ទ្រីលានយ័ន (1.94 ទ្រីលានដុល្លារ) កើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ 0.1% ។ ការចំណាយថវិកាសាធារណៈទូទៅរបស់ជាតិមានចំនួន 16.0737 ទ្រីលានយ័ន (2.3 ទ្រីលានដុល្លារ) កើនឡើង 3.4% ពីមួយឆ្នាំទៅមួយឆ្នាំ។ អ្នកគោលនយោបាយចិន បានផ្លាស់ប្តូរគោលដៅថវិកាជាតិទៅកាន់វិនិយោគប្រជាជន (China's Fiscal Focus Shifts to 'Investing in People)។

ការប្តូរគោលដៅថវិកាជាតិ ទៅកាន់វិនិយោគប្រជាជន (China's Fiscal Focus Shifts to 'Investing in People) យោងតាម លោក Peng Sen ប្រធានគណៈកម្មការកំណែទម្រង់សេដ្ឋកិច្ចចិន បាននិយាយថាអាជ្ញាធរគួរតែខិតខំប្រឹងប្រែងដើម្បីបង្កើនការប្រើប្រាស់ Consumption ជាចំណែកនៃផលិតផលក្នុងស្រុកសរុបដល់ 70% នៅឆ្នាំ 2035 ពីប្រហែល 55% នាពេលបច្ចុប្បន្ន។ ការបង្កើនការប្រើប្រាស់ Consumption គឺត្រូវតាមទ្រឹស្តីរបស់ Keynes ដែលដើម្បីបង្កើនកំណើនសេដ្ឋកិច្ច គឺត្រូវបង្កើនការប្រើប្រាស់ និងការវិនិយោគ។

តម្លៃមាសកំពុងឡើងថ្លៃ ដោយបំបែកកំណត់ត្រាក្នុងឆ្នាំនេះ និងផ្តល់ផលរំខានដល់ក្រុមហ៊ុនរុករករ៉ែ ខណៈដែលធនាគារកណ្តាល និងអ្នកវិនិយោគស្វែងរកសុវត្ថិភាព ចំពេលមានភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ច និងការធ្លាក់ចុះនៃប្រាក់ដុល្លារអាមេរិក។ តម្លៃមាស បានឡើងដល់ 3,500 ដុល្លារ ក្នុងមួយអោន

ដោយសារ ជម្លោះភូមិសាស្ត្រនយោបាយ ផលប៉ះពាល់នៃការជំរុញរូបិយវត្ថុ និងការរំពឹងទុកកើនឡើងនៃការកាត់បន្ថយអត្រាការប្រាក់របស់ Federal Reserve របស់សហរដ្ឋអាមេរិក។

យើងឃើញថា ពេលមានវិបត្តិវិនិយោគិនក្នុងពិភពលោក តែងតែរកសុវត្ថិភាព នៃមូលនិធិ របស់ខ្លួនតាមរយៈការផ្ទេរជាមាស ឬដុល្លារ ដែលជារូបបិយប័ណ្ណមានលំនឹង ប៉ុន្តែការបានធ្វើឲ្យរូបិយប័ណ្ណ ឬមាសឡើងតម្លៃ។ ដើម្បីទប់អតិផរណាក្នុងសហរដ្ឋអាមេរិក Federal Reserve របស់សហរដ្ឋអាមេរិក នឹងតម្លើងការប្រាក់។ លោកប្រធានាធិបតីសហរដ្ឋអាមេរិក ជាប្រធានាធិបតី មាននិន្នាការសន្តិភាព បានកំពុងជួយបញ្ចប់ជម្លោះ រុស្ស៊ីអ៊ុយក្រែន និងថៃកម្ពុជា។

ដំណោះស្រាយតាមរយៈការទូតរបស់កម្ពុជា និងជាមួយនឹងការគិតគូរជ្រោមជ្រែងពី ម៉ាឡេស៊ី ប្រធាន អាស៊ាន ចិន និងជាពិសេសសហរដ្ឋអាមេរិក បានធ្វើឲ្យជម្លោះព្រំដែនជាមួយថៃបានធូរស្រាល រួមទាំងស្មារតីប្រយុទ្ធការពាររបស់កងទ័ពកម្ពុជា បានធ្វើឲ្យកម្ពុជាអាចមានលទ្ធភាពចរចារជាមួយថៃ។

**ប្រភពទិន្នន័យ &ព័ត៌មានៈ**

- Xinhua
- China National Bureau of Statistics
- Ministry of Commerce People Republic of China
- Statista
- China Foreign Exchange Trade System
- Tradingeconomics
- CNN
- The Bangkok Post
- Caixin
- atlanta
- ychart
- globaltime
- Nikkei

- U.S. Bureau of Economic Analysis
- Reuters